# សេចក្តីប្រកាស
# ជ្រើសរើសអ្នកបើកបរ និង នាំសារ

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ត្រូវការជ្រើសរើសអ្នកបើកបរ និង នាំសារ ដើម្បីបំរើការងារឲ្យវិទ្យាស្ថាន។ បេក្ខជនដែលត្រូវបានជ្រើសរើស ត្រូវមានភារកិច្ច និង មានលក្ខណៈសម្បត្តិដូចខាងក្រោម៖

**ភារកិច្ចទទួលខុសត្រូវសំខាន់ៗ៖**

- ទទួលខុសត្រូវខ្ពស់ក្នុងការបើកបរជូនបុគ្គលិក ភ្ញៀវ និងគណប្រតិភូ ជាតិនិងអន្តរជាតិ ប្រកបដោយវិជ្ជាជីវៈ មានសុវត្ថិភាពខ្ពស់ និងគោរពពេលវេលាឲ្យបានទៀងទាត់
- បញ្ជូន និងប្រមូលលិខិត ឯកសារ និងសំភារៈផ្សេងៗ
- ជូសជុលបឋម និងថែទាំយានយន្តឲ្យមានលក្ខណៈល្អប្រសើរជាប្រចាំ
- ជួយការងាររដ្ឋបាលផ្សេងៗតាមការចាត់ចែង និងការស្នើររបស់របស់មន្ត្រីរដ្ឋបាល។

**លក្ខណៈសម្បត្តិដែលត្រូវមាន៖**

- កំរិតវប្បធម៌មធ្យមសិក្សាបត្របឋមភូមិ
- មានចំណេះដឹងភាសាអង់គ្លេសកំរិតមូលដ្ឋាន
- មានបទពិសោធន៍ក្នុងការបើកបររយៈពេល២-៣ឆ្នាំ(ជាពិសេសបើកបរឲ្យថ្នាក់ដឹកនាំអង្គភាព)
- អាចបើកបរទោចក្រយានយន្តបាន
- ចេះជួសជុលយានយន្តកំរិតមូលដ្ឋាន និងមានការយល់ដឹងក្នុងការថែរទាំយានយន្ត
- មានប័ណ្ណបើកបរដែលមានសុពលភាព និងមានប្រវត្តិបើកបរល្អ
- ស្គាល់ទីតាំងភូមសាស្រ្តក្នុងរាជធានីភ្នំពេញ ខេត្ត (ជាពិសេសស្គាល់អស័យដ្ឋានក្រសួង ស្ថាប័ន រដ្ឋស្ថានទូត អង្គភាពជាតិ និងអន្តរជាតិ និងក្រុមហ៊ុនឯជននានា
- មានសុខភាព និងកាយសម្បទាមាំមួនឧស្សាហ៍ព្យាយាម អត់ធ្មត់នឹងការងារ និងមានអត្តចរិកល្អ។

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមដាក់ពាក្យសុំ ដោយភ្ជាប់មកជាមួយនូវប្រវត្តិរូបសង្ខេបដោយមានបិទរូបថតទំហំ ៤x៦សម ១ច្បាប់។ អត្តសញ្ញាណប័ណ្ណថតចម្លង១ច្បាប់។ ប័ណ្ណបើកបរថតចម្លង១ច្បាប់។ ឈ្មោះអ្នកធានានិងលេខទំនាក់ទំនងចំនួនបីរូបតាមរយៈអ៊ីម៉េល:hr@cdri.org.kh ឬតាមអស័យដ្ឋានផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទូលគោគ រាជធានីភ្នំពេញ ត្រឹមថ្ងៃទី**៣០ ខែមេសា ឆ្នាំ២០១៩**។

**បេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ នឹងត្រូវបានអញ្ជើញមកសម្ភាសន៍**
**ពាក្យស្នើរសុំនិងឯកសារភ្ជាប់មិនប្រគល់ជូនវិញទេ។**